តុលាការខេត្តបាត់ដំបង
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ : ៨១៤ ចុះថ្ងៃទី ២៨
ខែ តុលា ឆ្នាំ ២០០៥
**សាលក្រមព្រហ្មទណ្ឌ**
លេខ : ២៤ "ក" ចុះថ្ងៃទី ៣០
ខែ មករា ឆ្នាំ ២០០៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈនៅទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted]ជាប្រធានតុលាការខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមតុលាការខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**ដើម្បីជំនុំជំរះ**

រឿងក្តីព្រហ្មទណ្ឌលេខ ៨១៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ ។

១-ឈ្មោះ ទ សទ ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីធ្វើស្រែចំការ មានទីកន្លែងកំណើតនៅភូមិសំឡូត ឃុំស្ពៅ ស្រុករតនះមណ្ឌល ខេត្តបាត់ដំបង មានកំរិតវប្បធម៌ថ្នាក់ទី ៥ កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិតាគ្រក់ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង មានប្រពន្ធឈ្មោះ ត សទ (រ) មានកូន ០១នាក់ មានឪពុកឈ្មោះ ណា ទ (រ) ម្តាយឈ្មោះ ត សខ (រ) ទោសពីមុនគ្មាន ។ ត្រូវចាប់ខ្លួនកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៥ នៅចំណុចផ្ទះរបស់ជនជាប់ចោទ នៅភូមិតាគ្រក់ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង និង ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន នៅអាគារឃុំខ្លួនពន្ធនាគារខេត្តបាត់ដំបង តាមដីកាឃុំខ្លួនលេខ ២៤ ដ.ឃ.ខ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ ។

ត្រូវចោទពីបទ : **រក្សាទុក និង ប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់** តាមបទបញ្ញត្តិមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។ ប្រព្រឹត្តនៅភូមិតាគ្រក់ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ។

**ការប្រព្រឹត្តិទៅរបស់ជនជាប់ចោទ**

កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោង ៥ល្ងាច ឈ្មោះ ទ សទ បានឈ្លោះប្រកែកគ្នាជាមួយ ឈ្មោះ ត ខមរ នៅនឹងតូបលក់ឥវ៉ាន់ចាប់ហួយ ។ ក្រោយ

មកឈ្មោះ ទ សខ បានទៅយកកាំភ្លើងអាកាមួយដើម ដែលលាក់ទុកយូរហើយមកបាញ់ឡើងលើចំនួន ០៣គ្រាប់ ។

-តាមរបាយការណ៍ព្រឹត្តិហេតុលេខ : ៩៩/០៥ ន.ម.ត ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ របស់នគរបាលរដ្ឋបាលឃុំគ្រែង បានបញ្ជាក់ថា នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោង ១៧ មានឈ្មោះ ទ សខ ភេទប្រុស អាយុ ២២ឆ្នាំ រស់នៅភូមិតាគ្រក់ ឃុំគ្រែង ស្រុករតនមណ្ឌល បានឈ្លោះជាមួយឈ្មោះ ត ខមរ ភេទប្រុស អាយុ ២៣ឆ្នាំ រស់នៅភូមជាមួយគ្នា ពេលនោះឈ្មោះ ទ សខ បានខឹងក៏រត់ទៅយកកាំភ្លើង ដែលខ្លួនលាក់ទុកក្នុងព្រៃយកមកបាញ់ទៅលើចំនួន ០៣គ្រាប់ រួចយកកាំភ្លើងលាក់ទុកក្នុងព្រៃវិញ ។

-តាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ របស់អយ្យការអមតុលាការខេត្តបាត់ដំបង បានបញ្ជាក់ថា បានទទួលអាវុធអាកាបត់មួយដើមលេខ ៣៧៩៥ ផលិតនៅប្រទេសចិន បង់ខ្ចីមួយ គ្រាប់ ០៣គ្រាប់ ។

## នៅចំពោះមុខតុលាការនាពេលសវនាការ

-ជនជាប់ចោទឈ្មោះ ទ សខ បានឆ្លើយសារភាពថា : កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោង ៥ ខ្លួនពិតជាបានយកកាំភ្លើងបាញ់ឡើងលើចំនួន ០៣គ្រាប់មែន តែមិនមែនបាញ់គំរាមអ្នកណាទេ ។ កាំភ្លើងនោះខ្លួនបានរើសបាននៅក្នុងព្រៃ ហើយលាក់ទុកដើម្បីបាញ់សត្វ ។

-តាមចម្លើយសាក្សីឈ្មោះ ត ខមរ បានបញ្ជាក់ថា : នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោងប្រហែល ១៧ ខ្លួនបានដើរទៅអង្គុយលេងនៅតូបលក់ឥវ៉ាន់របស់ឈ្មោះ ញ ច ពេលនោះខ្លួនឃើញសៀវភៅបញ្ជីអ្នកជំពាក់ប្រាក់យកមកអានឮៗ ដោយអានចំឈ្មោះតា ទ ជាឪពុករបស់ឈ្មោះ ទ សខ ដែលពេលនោះឈ្មោះ ទ សខ ឮបានគំរាមកំហែងរករឿងខ្លួន ហើយឈ្មោះ ទ សខ ដើរទៅផ្ទះតា ឆ យកកាំភ្លើងអាកាមកបាញ់ឡើងលើគំរាមខ្លួន ។

-តាមចម្លើយសាក្សីឈ្មោះ ត សជ បានបញ្ជាក់ថា កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ម៉ោងប្រហែល ១៧ ខ្លួនកំពុងអង្គុយ ស្រាប់តែឮសូរកាំភ្លើងចំនួន ០៣គ្រាប់ នៅក្រោយផ្ទះរបស់ឈ្មោះ ច ហើយឈ្មោះ ត ខមរ បានប្រាប់ខ្លួនថា ឈ្មោះ ទ សខ បានយកកាំភ្លើងបាញ់គំរាមខ្លួន ។

## តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា

ពិតជាមានអំពើល្មើសច្បាប់ព្រហ្មទណ្ឌ គឺបទប្រើប្រាស់ និង រក្សាទុកអាវុធហាមឃាត់ ដោយខុសច្បាប់ ប្រព្រឹត្តនៅភូមិតាគ្រក់ ឃុំស្ពោ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ។ ដែលត្រូវផ្ដន្ទាទោសតាមមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ភស្តុតាងដាក់បន្ទុកមាន ចម្លើយរបស់ជនជាប់ចោទ ចម្លើយសាក្សី វត្ថុតាងដែលដកហូតបាន គឺកាំភ្លើងមួយដើម ។ ក្នុងនាមតំណាងអយ្យការ សុំតម្កល់បទចោទទុកជាបានការពេញទាំងមូល និង ស្នើសុំតុលាការផ្ដន្ទាទោសឈ្មោះ ទ សខ ដាក់ពន្ធនាគារកំណត់ពី ០១ឆ្នាំ ដល់ ០៣ឆ្នាំ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ ទ សខ បាននិយាយជាសំដីចុងក្រោយថា សុំតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ដល់ខ្លួនផង ។



Scanned with CamScanner

-បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ
-បានស្តាប់ចម្លើយឱ្យការណ៍របស់សាក្សី
-បានស្តាប់ការសួរដេញដោល
-បានពិនិត្យកំណត់ហេតុ ឯកសារ ភស្តុតាងនានា
-បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ
-បានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការខេត្តបាត់ដំបងយល់ឃើញថា**

-ពិតជាកើតមាននូវអំពើរក្សាប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ នៅភូមិតាគ្រក់ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ប្រាកដមែន ។
-អំពើរក្សា ប្រើប្រាស់អាវុធហាមឃាត់ដោយខុសច្បាប់ដែលកើតមាននៅទីកន្លែង និង ពេលវេលាដូច ខាងលើ ពិតជាប្រព្រឹត្តឡើងដោយឈ្មោះ ខ សខ ប្រាកដមែន ។
-អំពើដែលឈ្មោះ ខ សខ បានប្រព្រឹត្តនៅទីកន្លែង និងពេលវេលាដូចខាងលើនេះ មានធាតុផ្សំគ្រប់គ្រាន់ ជាបទរក្សាប្រើប្រាស់អាវុធហាមឃាត់ដោយខុសច្បាប់ដូចមានបញ្ញត្តិក្នុងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។ ជនជាប់ចោទជាសមត្ថជន គាត់មានអាយុ ២៤ឆ្នាំ មានស្មារតីជានាល្អ គាត់បានប្រព្រឹត្ត អំពើដោយចេតនារក្សាទុក ប្រើប្រាស់អាវុធកាំភ្លើងអាកាស្វាយបត់មួយដើមនៅនឹងផ្ទះខ្លួន និង នៅក្នុង ព្រៃ និង បានប្រើបាញ់គម្រាមអ្នកភូមិជាមួយដោយខុសច្បាប់ ។

**យល់ឃើញថា**

មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ ខ សខ ពីបទរក្សា ប្រើប្រាស់អាវុធហាមឃាត់ដោយខុស ច្បាប់ ប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចការចោទប្រកាន់របស់ស្ថាប័នអយ្យការប្រាកដមែន ។

**ភស្តុតាងដាក់បន្ទុកមាន :**

-ចម្លើយរបស់ជនជាប់ចោទ ខ សខ ថាខ្លួនបានរើសបានកាំភ្លើងអាកាបត់មួយដើម មានបង់ដាក់គ្រាប់មួយ គ្រាប់ ០៦គ្រាប់ ពីព្រៃភ្នំស្រង់ រួចយកមករក្សាទុកនៅនឹងផ្ទះរបស់ខ្លួន ទុកដើម្បីឆ្មុះសត្វ ដល់ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ខ្លួនបានយកកាំភ្លើងនោះបាញ់សាកលមើល ក៏ត្រូវនាក់ជិតខាងប្តឹងសមត្ថកិច្ច ចាប់ខ្លួនបញ្ជូនមកតុលាការ ។
-ចម្លើយឱ្យការណ៍របស់សាក្សីឈ្មោះ គ រគន និង ឈ្មោះ គ សឌ បានឆ្លើយបញ្ជាក់យ៉ាងច្បាស់អំពី អំពើដែលជនជាប់ចោទបានប្រព្រឹត្ត គឺឈ្មោះ ខ សខ បានរត់ទៅយកកាំភ្លើងពីផ្ទះឈ្មោះ ច មកបាញ់ គម្រាមចំនួន ០៣គ្រាប់ ចម្លើយនេះវាស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទ និង ហេតុការណ៍ កាលៈទេសៈ នៃបទល្មើស ។
-កំណត់ហេតុ ឯកសារភស្តុតាងនានាធ្វើដោយនគរបាលយុត្តិធម៌ ។
-វត្ថុតាងមានកាំភ្លើងចុនអាកាស្វាយបត់មួយដើម មានលេខតួ ៣៧៩៥ ផលិតនៅប្រទេសចិន បង់ដាក់ គ្រាប់មួយ គ្រាប់ចំនួន ០៣គ្រាប់ គុណភាពចាស់ ត្រូវរឹបអូសរួចបំផ្លាញចោល ។



Scanned with CamScanner

## <u>យល់ឃើញថា</u>

ជនជាប់ចោទបានប្រើកាំភ្លើងខុសច្បាប់បាញ់សំឡុតគម្រាមអ្នកដទៃ ជាហេតុតុលាការយកមកពិចារណាជាស្ថានទម្ងន់ទោសក្នុងការសំរេចពីទណ្ឌកម្ម ។

ជនជាប់ចោទជាជនមិនដែលមានទោសពីមុនមក គាត់ជាជនមានកិរិតវប្បធម៌ទាប ស្ថានទាំងនេះអាចឱ្យតុលាការយកមកពិចារណាជាស្ថានសម្រាលទោសឱ្យគាត់បាន ។

## <u>ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោស : ឈ្មោះ ខ សខ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំគត់ ដោយគិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ ។ ពីបទ : **រក្សាទុក និង ប្រើប្រាស់អាវុធហាមឃាត់ដោយខុសច្បាប់** ប្រព្រឹត្តនៅភូមិតាគ្រក់ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ។ បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោសមានបញ្ញត្តិក្នុងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-វត្ថុតាងមានកាំភ្លើងធុនអាកាស្វាយបត់មួយដើមផលិតនៅប្រទេសចិន មានលេខតួ ៣៧៩៥ បង់ដាក់គ្រាប់មួយ គ្រាប់ចំនួន ០៣គ្រាប់ ត្រូវរឹបអូសបំផ្លាញចោល ។

៣-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ **ខ សខ** ។ បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជំរះ**

[redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលក្រម ឱ្យសំរេចតាមសាលក្រមនេះ និង ឱ្យអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ជួយអនុវត្តឱ្យបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៦*

**ជ.ក្រឡាបញ្ជីសវនាការ**

**បានឃើញ**

*បាត់ដំបង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៦*

**ប្រធានតុលាការខេត្ត**

[redacted]

Scanned with CamScanner